# ករណីសិក្សា
# ការព្រមព្រៀងលើលទ្ធផលដាក់ពិន្ទុឃុំអូរសណ្ដាន់ ស្រុកក្រគរ

ដំណើរការនៃការដាក់ពិន្ទុសហគមន៍ជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពមួយដែលប្រជាពលរដ្ឋភាគច្រើនមានការពេញចិត្តទៅលើវិធីសាស្ត្រនេះក្នុងការវាយតម្លៃទៅលើគុណភាពនៃការផ្ដល់សេវារបស់ក្រុមប្រឹក្សាឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាព។ ដំណើរការនៃការដាក់ពិន្ទុនេះ អ្នកផ្ដល់សេវាមួយចំនួននៅមានភាពអល់អែកក្នុងការទទួលយកនូវយោបល់ត្រឡប់ពីប្រជាពលរដ្ឋទៅលើលទ្ធផលនៃការដាក់ពិន្ទុ។

ជាក់ស្ដែង នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤ ក្រុមប្រឹក្សាឃុំអូរសណ្ដាន់បានរៀបចំកិច្ចប្រជុំរួមរវាងអ្នកផ្ដល់សេវា និងអ្នកទទួលសេវាក្រុមប្រឹក្សាឃុំអូរសណ្ដាន់សម្របសម្រួលដោយអ្នកសម្របសម្រួលសហគមន៍ និងគាំទ្របច្ចេកទេសដោយអង្គការអនាគតកុមារ។ អ្នកសម្របសម្រួលអញ្ជើញតំណាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំឡើងបង្ហាញនូវផែនការសកម្មភាពជាអាទិភាពរបស់ខ្លួនម្ដងម្នាក់ៗ។ ក្រោយពីបង្ហាញចប់ ក្រុមប្រឹក្សាឃុំពុំព្រមទទួលយកទៅលើលទ្ធផលដែលដាក់ពិន្ទុដោយប្រជាពលរដ្ឋទេទៅលើសកម្មភាពក្រុមប្រឹក្សាឃុំចុះប្រជុំពិគ្រោះយោបល់នៅមូលដ្ឋានដោយពិន្ទុមធ្យមរបស់ក្រុមប្រឹក្សា៤,៥ និងរបស់ប្រជាពលរដ្ឋ ២,៤១។

អ្នកសម្របសម្រួលសហគមន៍បានអញ្ជើញអ្នកផ្ដល់សេវា និងអ្នកទទួលសេវាឡើងបង្ហាញអំពីបានធ្វើការសម្របសម្រួលដល់ភាគីអ្នកផ្ដល់សេវា និងភាគីអ្នកទទួលសេវាដោយឱ្យភាគីទាំងសងខាងលើកយកនូវហេតុផល និងអំណះអំណាងនៃការដាក់ពិន្ទុរបស់ខ្លួនមកបង្ហាញ និងបញ្ជាក់។



ជាដំបូង លោក លឹម សារឹម សមាជិកក្រុមប្រឹក្សាឃុំបានលើកយកហេតុផល ចំពោះការដាក់ ពិន្ទុរបស់ខ្លួនថា បានជាក្រុមប្រឹក្សាហ៊ានដាក់ពិន្ទុដូចច្នេះដោយសារសកម្មភាពនេះ ក្រុមប្រឹក្សាឃុំបានចុះធ្វើការប្រជុំពិគ្រោះយោបល់នៅមូលដ្ឋានជាមួយប្រជាពលរដ្ឋជាញឹកញាប់ ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនមិនបានមកចូលរួមប្រជុំជាមួយក្រុមប្រឹក្សាទេ ដែលជាហេតុធ្វើ ឱ្យពួកគាត់មិនបានដឹងពីការចុះពិគ្រោះយោបល់។

បន្ទាប់មក លោក ហង្ស សួន សមាជិកក្រុមប្រឹក្សាឃុំ មានមតិចូលរួមផងដែរថា ការចុះពិគ្រោះយោបល់របស់ក្រុមប្រឹក្សាឃុំជាមួយប្រជាពលរដ្ឋគឺពិតជាបានធ្វើញឹកញាប់ណាស់មិនថាការចុះជួបលក្ខណៈជាក្រុម ឬក៏ជាបុគ្គលនោះទេ ហើយក្រុមប្រឹក្សាក៏បានរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ថែមទៀតផងដើម្បីផ្ដល់ឱកាសឱ្យប្រជាពលរដ្ឋលើកឡើង ពីបញ្ហា ក្ដីកង្វល់ និងតម្រូវការជាអាទិភាពរបស់ពួកគេដាក់ជូនក្រុមប្រឹក្សា និងវាគ្មិនជួយធ្វើការដោះស្រាយ។

# ករណីសិក្សា
# ការព្រមព្រៀងលើលទ្ធផលដាក់ពិន្ទុឃុំអូរសណ្ដាន់ ស្រុកក្រគរ

ប្រជាពលរដ្ឋអ្នកទទួលសេវាលោក**អ៊ុំ ខាន់** ប្រជាពលរដ្ឋរស់នៅភូមិពុទ្រាមបានលើកឡើងថាបាន ជាប្រជាពលរដ្ឋដាក់ពិន្ទុដូចនេះដល់ក្រុមប្រឹក្សាឃុំលើ ការចុះពិគ្រោះយោបល់នៅមូលដ្ឋានដោយសារមាន ប្រជាពលរដ្ឋតិចតួចណាស់ដែលបានចូលរួម និងអ្នកខ្លះ ក៏មិនបានដឹងពីព័តិមាននៃកិច្ចប្រជុំនេះទេ ម្យ៉ាងទៀត ការប្រជុំនេះធ្វើឡើងមិនសូវបានញឹកញាប់ទេនៅតាម ភូមិ ភូមិខ្លះបានចំនួនពីរទៅបីដងប៉ុណ្ណោះក្នុងមួយឆ្នាំ។ បំណងរបស់ប្រជាពលរដ្ឋ គឺចង់អោយក្រុមប្រឹក្សាឃុំ ចុះពិគ្រោះយោបល់នៅមូលដ្ឋានឱ្យបានយ៉ាងតិចក៏ម្ដង ដែរក្នុងមួយខែដើម្បីឱ្យប្រជាពលរដ្ឋបានដឹងអំពីព័តិមានរបស់ក្រុមប្រឹក្សា ដូចជាការផ្ដល់សេវារបស់ឃុំ និងសមិទ្ធផលនានា ដែលឃុំបានធ្វើ ព្រមទាំងអាចជាឱកាសសម្រាប់ឱ្យប្រជាពលរដ្ឋបានលើកពីបញ្ហា ក្ដីកង្វល់ នឹងតម្រូវការជាអាទិភាពជូនក្រុមប្រឹក្សាឃុំដោះស្រាយ។



កិច្ចប្រជុំរួម ឃុំ អូរសណ្ដាន់ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤

ក្រោយពីបានស្ដាប់ហេតុផលរបស់ភាគីអ្នកផ្ដល់សេវា និងអ្នកទទួលសេវាឃុំរួចមក អ្នកសម្របសម្រួលបញ្ជាក់ភាគីទាំងសងខាងម្ដងទៀតថាតើភាគីទាំង២ អាចទទួលយកលទ្ធផលនៃការដាក់ពិន្ទុរបស់ខ្លួនដែរឬទេព្រោះលទ្ធផលនេះមិនមែនជាការចាប់កំហុសឬការតិះទៀនដល់ក្រុមប្រឹក្សាឃុំទេ ផ្ទុយទៅវិញការដាក់ពិន្ទុដល់សេវារបស់ឃុំនេះជាឱកាសសម្រាប់ក្រុមប្រឹក្សាឃុំក្នុងការធ្វើការកែសម្រួលនូវការផ្ដល់សេវារបស់ខ្លួនទៅដល់ប្រជាពលរដ្ឋឱ្យកាន់តែមានគុណភាពជាងមុន។ បន្ទាប់មកឃើញថា លោក ម៉ម ធន ប្រធានក្រុមប្រឹក្សាឃុំអូរសណ្ដាន់បាន យល់ព្រមទទួលយកនូវលទ្ធផលនៃការដាក់ពិន្ទុរបស់ប្រជាពលរដ្ឋទៅលើការផ្ដល់សេវារបស់ឃុំ។ លោកបានដាក់បញ្ចូលក្នុងផែនការសកម្មភាពគណនេយ្យភាពរួមដោយក្រុមប្រឹក្សាឃុំត្រូវចុះជួបសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានយ៉ាងតិចក៏ម្ដងដែរក្នុង១ខែ។

នៅចុងបញ្ចប់នៃការប្រជុំរវាងអ្នកផ្ដល់សេវា និងអ្នកទទួលសេវាបានព្រមព្រៀងគ្នាទៅលើចំណុចដែលត្រូវកែលំអរ និងចូលរួមទាំងអស់គ្នាដើម្បីធានាថារាល់សកម្មភាពដែលជាអាទិភាពដែលលើកឡើងដោយប្រជាពលរដ្ឋនឹងអនុវត្តដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ដំណើរការនៃការដាក់ពិន្ទុសហគមន៍មានសារៈយ៉ាងខ្លាំងទាំងអ្នកផ្ដល់សេវា និងអ្នកទទួលសេវាដើម្បីធានាថាការផ្ដល់សេវារបស់ក្រុមប្រឹក្សាជូនដល់ប្រជាពលរដ្ឋមានមានគុណភាព និងបានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋបានល្អប្រសើរជាងមុន។